# ពិធីការទីធ្លាបោះជំរុំ និងសួនឧទ្យាន RV: ឧបសម្ព័ន្ធ ០

**ការធ្វើបច្ចុប្បន្នភាពថ្មីៗ ថ្ងៃទី 12/6/20:**

- កន្លែងបោះជំរំ និងសួនកម្សាន្ត RV មិនត្រូវអនុញ្ញាតិអោយភ្ញៀវស្នាក់នៅមួយយប់ក្នុងគោលបំណងកំសាន្តសប្បាយឡើយ។ កន្លែងបោះជំរុំ និងសួនឧទ្យាន RV ត្រូវបានអនុញ្ញាតិឱ្យផ្តល់កន្លែងស្នាក់នៅ សម្រាប់វិធានការណ៍កាត់បន្ថយ និងទប់ស្កាត់ជំងឺ COVID-19, វិធានការណ៍ព្យាបាល, កន្លែងស្នាក់នៅសម្រាប់កម្មករសំខាន់/ចាំបាច់, ឬសម្រាប់ផ្តល់ដំណោះស្រាយហៅស៊ីង/លំនៅដ្ឋាន, រួមទាំងវិធានការណ៍ដើម្បីការពារប្រជាជនដែលគ្មានផ្ទះ សម្បែង ដែលទាំងនោះ ត្រូវបានគេចាត់ទុកថាជាអាជីវកម្មដ៏សំខាន់/ចាំបាច់។ ការផ្លាស់ប្តូរ គឺបានគូសបញ្ជាក់ពណ៌លឿង។

តំរូវការនានាខាងក្រោមនេះ មានលក្ខណៈជាក់លាក់ចំពោះទីធ្លាបោះជំរុំ និងសួនឧទ្យាន RV ដែលមានការអនុញ្ញាតិអោយបើក ដោយបទបញ្ជារបស់មន្ត្រីសុខភាពសាធារណៈរដ្ឋ។ បន្ថែមពីលើលក្ខ័ណ្ឌ ដែលបានដាក់នៅតាមកន្លែងជាក់លាក់នានាដោយអភិបាលរដ្ឋ, ប្រភេទអាជីវកម្មទាំងនេះ ត្រូវតែគោរពតាមលក្ខ័ណ្ឌនានា ដែលមានចែងនៅក្នុងបញ្ជីផ្ទៀងផ្ទាត់នេះ។

កន្លែងបោះជំរំ និងសួនកម្សាន្ត RV មិនត្រូវអនុញ្ញាតិអោយភ្ញៀវស្នាក់នៅមួយយប់ក្នុងគោលបំណងកំសាន្តសប្បាយឡើយ។ កន្លែងបោះជំរុំ និងសួនឧទ្យាន RV ត្រូវបានអនុញ្ញាតិឱ្យផ្តល់កន្លែងស្នាក់នៅ សម្រាប់វិធានការណ៍កាត់បន្ថយ និងទប់ស្កាត់ជំងឺ COVID-19, វិធានការណ៍ព្យាបាល, កន្លែងស្នាក់នៅសម្រាប់កម្មករសំខាន់/ចាំបាច់, ឬសម្រាប់ផ្តល់ដំណោះស្រាយហៅស៊ីង/លំនៅដ្ឋាន, រួមទាំងវិធានការណ៍ដើម្បីការពារប្រជាជនដែលគ្មានផ្ទះ សម្បែង ដែលទាំងនោះ ត្រូវបានគេចាត់ទុកថាជាអាជីវកម្មដ៏សំខាន់/ចាំបាច់។ ទីធ្លាបោះជំរុំ និងសួនឧទ្យាន RV ត្រូវតែបិទនៅចន្លោះម៉ោង ១០ យប់ រហូតដល់ម៉ោង ៥ ព្រឹក។

សូមកត់សំគាល់៖ ឯកសារនេះអាចត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលព័ត៌មាន និងធនធាននានាបន្ថែមទៀត អាចរកបាន ដូច្នេះត្រូវប្រាកដថា នឹងពិនិត្យមើលលើគេហទំព័រឡងប៊ិច COVID-19 នៅឯ www.longbeach.gov/covid19 ជាប្រចាំ ដើម្បីទទួលបានព័ត៌មានថ្មីៗ ចំពោះឯកសារនេះ។

បញ្ជីផ្ទៀងផ្ទាត់នេះ រួមមាននូវ៖

(1) គោលនយោបាយនានា និងការអនុវត្តនៅកន្លែងធ្វើការ ដើម្បីការពារសុខភាពនិយោជិក

(2) វិធានការណ៍នានា ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា

(3) វិធានការណ៍នានា ដើម្បីធានាការគ្រប់គ្រងការឆ្លង

(4) ការប្រាស្រ័យទាក់ទងជាមួយនិយោជិក និងសាធារណៈជន

(5) វិធានការណ៍នានា ដើម្បីធានាបាននូវការទទួលបាននូវសេវាកម្មចាំបាច់ ប្រកបដោយសមធម៌

ផ្នែកសំខាន់ៗទាំងប្រាំនេះ ត្រូវតែបានដោះស្រាយខណៈពេលដែលកន្លែងរបស់អ្នក អភិវឌ្ឍនូវពិធីការបើកឡើងវិញនោះ។

**ទីធ្លាបោះជំរុំ និងសួនឧទ្យាន RV ទាំងអស់ ដែលបានស្ថិតនៅក្នុងគោលការណ៍ណែនាំនេះ ត្រូវអនុវត្តនូវរាល់វិធានការណ៍នានា ដែលអាចអនុវត្តបាន ដែលមានរាយខាងក្រោម ហើយត្រៀមក្នុងការពន្យល់ អំពីមូលហេតុអ្វី បានជាវិធានការណ៍ណាមួយដែលមិនត្រូវបានអនុវត្តនោះ មិនអាចអនុវត្តបាន។**

**ឈ្មោះកន្លែង:** ______________________________

**អាសយដ្ឋានកន្លែង:** ______________________________

**A. គោលនយោបាយកន្លែងធ្វើការ និងវិធានការណ៍នានា ដើម្បីការពារសុខភាពនិយោជិក (គូសទាំងអស់ដែលអនុវត្តចំពោះទីកន្លែង)**

- ❑ មនុស្សគ្រប់រូបដែលអាចបំពេញភារៈកិច្ចការងាររបស់ពួកគេពីផ្ទះ ត្រូវបានគេណែនាំអោយធ្វើដូច្នេះ។
- ❑ បុគ្គលិកដែលងាយរងគ្រោះ (អ្នកដែលមានអាយុលើសពី ៦៥ ឆ្នាំ, អ្នកដែលមានលក្ខ័ណ្ឌសុខភាពរ៉ាំរ៉ៃ) ត្រូវបានចាត់តាំងអោយធ្វើការដែលអាចធ្វើបានពីផ្ទះ នៅពេលណាដែលអាចធ្វើទៅបាន។
- ❑ ដំណើរការការងារត្រូវបានកំណត់ឡើងវិញតាមលទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីបង្កើនឱកាសសម្រាប់និយោជិកធ្វើការពីផ្ទះ។ ពិចារណាផ្តល់ជូនកម្មករ, ដែលស្នើសុំជម្រើសភារៈកិច្ច ដែលបានកែប្រែដែលកាត់បន្ថយនូវទំនាក់ទំនងរបស់ពួកគេ ជាមួយភ្ញៀវ និងនិយោជិកផ្សេងទៀត។
- ❑ កាលវិភាគឆ្លាស់គ្នា, បន្តរបន្ទាប់គ្នា ឬប្តូរវេន ត្រូវបានបង្កើតឡើង ដើម្បីពង្រីកគំលាតឆ្ងាយរាងកាយពីគ្នា។
- ❑ និយោជិកទាំងអស់ (រាប់បញ្ចូលទាំងបុគ្គលិកដែលទទួលបានប្រាក់ឈ្នួល, និងអ្នកស្ម័គ្រចិត្ត; ដែលត្រូវបានសំដៅជាសមូហភាព ថាជា "និយោជិក") ត្រូវបានគេប្រាប់ថា មិនឱ្យមកធ្វើការប្រសិនបើឈឺ ឬប្រសិនបើពួកគេត្រូវបានប៉ះពាល់ នឹងអ្នកដែលមានជំងឺ

COVID-19។ និយោជិក យល់ថាត្រូវធ្វើតាមបទបញ្ជារបស់មន្ត្រីសុខភាពទីក្រុងឡុងប៊ីឆ សំរាប់ការដាក់ខ្លួនអោយនៅឯកោ និង ការដាក់ខ្លួនអោយនៅឃ្លាតឆ្ងាយពីអ្នកដទៃ, ប្រសិនបើអាចធ្វើទៅបាន។ គោលនយោបាយឈប់សម្រាកនៅកន្លែងធ្វើការត្រូវ បាន ពិនិត្យ និងកែប្រែ ដើម្បីធានាថាអ្នកធ្វើការមិនត្រូវបានពិន័យ នៅពេលពួកគេស្នាក់នៅផ្ទះដោយសារជំងឺនោះឡើយ។

- សូមមើលព័ត៌មានបន្ថែម ស្តីពីកម្មវិធីរបស់រដ្ឋាភិបាល ដែលគាំទ្រការឈប់សម្រាកឈឺ និងសំណងរបស់កម្មករសម្រាប់ជំងឺ COVID19, រួមមានសិទ្ធិឈប់សម្រាកឈឺរបស់និយោជិក ក្រោមច្បាប់ឆ្លើយតបជំងឺខូរ៉ូណាវីរុសគ្រួសារជាចំបង និងសិទ្ធិរបស់និយោជិក ចំពោះអត្ថប្រយោជន៍សំណងរបស់កម្មករ និងការសន្មតថា ការងារដែលជាប់ទាក់ទងនឹងជំងឺ COVID-19 ដោយអនុលោមតាមបទបញ្ជាប្រតិបត្តិរបស់អភិបាលរដ្ឋ លេខ N-62-20។

- ❑ នៅពេលទទួលបានដំណឹងថានិយោជិកម្នាក់ ឬច្រើននាក់ ធ្វើតេស្តវិជ្ជមាន, ឬមានរោគសញ្ញាស្របគ្នាទៅនឹងជំងឺ COVID-19 (ករណី), និយោជកត្រូវមានផែនការ ឬពិធីសារដើម្បីអោយករណីដាក់ខ្លួនគេអោយនៅឯកោនៅផ្ទះ ហើយតម្រូវអោយមានការ ដាក់អោយនៅឃ្លាតដាច់ឆ្ងាយពីគេខ្លួនឯងភ្លាមៗចំពោះ ឬនៃនិយោជិកទាំងអស់ ដែលមានការប្រឈមនៅនឹងកន្លែងធ្វើការ ទៅ នឹងករណី។ ផែនការរបស់និយោជក គួរតែពិចារណាលើពិធីការសម្រាប់និយោជិកដែលបានដាក់ខ្លួនអោយនៅឃ្លាតដាច់ឆ្ងាយពី គេទាំងអស់មានលទ្ធភាពធ្វើតេស្ត ឬត្រូវបានធ្វើតេស្ត សំរាប់ជំងឺ COVID-19 ដើម្បីកំណត់ថា តើមានការប្រឈមនៅកន្លែងធ្វើ ការបន្ថែមទៀត, ដែលអាចតម្រូវឱ្យមានវិធានការណ៍ត្រួតពិនិត្យជំងឺ COVID-19 បន្ថែម។
- ❑ ការត្រួតពិនិត្យរោគសញ្ញា ត្រូវបានធ្វើឡើងមុនពេលនិយោជិកអាចចូលធ្វើការ។ ការត្រួតពិនិត្យត្រូវ តែរាប់បញ្ចូលទាំងការសួរនាំ ឬផ្នែកឆេះទាក់ទងទៅនឹងការក្អក, ដង្ហើមខ្លី/ដង្ហក់ ឬគ្រុនក្តៅ និងរោគសញ្ញាផ្សេងទៀត ដែលបុគ្គលិកអាចនឹងកំពុងជួបប្រទះ។ ការត្រួតពិនិត្យទាំងនេះ អាចត្រូវបានធ្វើឡើងពីចម្ងាយ ឬដោយផ្ទាល់ នៅពេលមកដល់របស់និយោជិក។
- ❑ ការត្រួតពិនិត្យសីតុណ្ហភាព គួរតែត្រូវបានធ្វើនៅកន្លែងធ្វើការ ប្រសិនបើអាចធ្វើទៅបាន។
- ❑ ក្នុងករណីដែលមានករណីចំនួន ៣ ឬច្រើនជាងនេះ ត្រូវបានរកឃើញនៅក្នុងកន្លែងធ្វើការក្នុងរយៈពេល ១៤ ថ្ងៃ និយោជកគួរតែរាយការណ៍ពីចង្កោមហេតុការណ៍នេះ ទៅមន្ទីរសុខាភិបាល និងសេវាមនុស្សនៃទីក្រុងឡុងប៊ិច តាមលេខ ៥៦២-៥៧0-INFO។
- ❑ និយោជិកទាំងអស់ដែលមានទំនាក់ទំនងជាមួយសាធារណៈជន ឬនិយោជិកផ្សេងទៀត ក្នុងកំឡុងវេនរបស់ពួកគេ ត្រូវបានផ្តល់ជូន, ដោយឥតគិតថ្លៃ, ចំពោះគម្របមុខ។ គម្របមុខ គឺត្រូវពាក់ដោយនិយោជិកគ្រប់ពេលវេលាទាំងអស់ នៅពេលថ្ងៃធ្វើការ នៅពេលមានការប៉ះពាល់ ឬទំនងជាទាក់ទងជាមួយអ្នកដទៃ, និយោជិកមិនចាំបាច់ពាក់គម្របមុខក្រណាត់នោះទេ នៅពេលនិយោជិកនៅម្នាក់ឯង ក្នុងការិយាល័យឯកជន ឬគូបដែលមានជញ្ជាំង។
- ❑ និយោជិកត្រូវបានណែនាំ អោយលាងសំអាតគម្របមុខរបស់ពួកគេជារៀងរាល់ថ្ងៃ។
- ❑ ផងដែរ និយោជិកត្រូវបានគេផ្តល់ស្រោមដៃអោយ សម្រាប់ភារៈកិច្ចដែលតម្រូវអោយពួកគេធ្វើការជាមួយនឹង ផ្ទៃដែលប៉ះពាល់ជាញឹកញាប់ ឬសម្រាប់ប្រើក្នុងកំឡុងពេលពិនិត្យនូវរោគសញ្ញា។

- ❑ និយោជិកត្រូវបានណែនាំអោយរក្សាចម្ងាយយ៉ាងតិចប្រាំមួយ (៦) ហ្វីត ពីអតិថិជននិ ងពីគ្នាទៅវិញទៅមក, លើកលែងតែនិយោ ជិកចូលមកជិតមួយភ្លែត នៅពេលមានការចាំបាច់ ដើម្បីទទួលយកការទូទាត់, ប្រគល់ទំនិញ ឬសេវាកម្ម ឬតាមការចាំបាច់នានា។
- ❑ បន្ទប់ទឹក និងកន្លែងទូទៅផ្សេងទៀត ត្រូវបានគេសំឡាប់មេរោគជាញឹកញាប់, តាមកាលវិភាគដូចខាងក្រោមៈ
  - ○ បន្ទប់ទឹក ________________________________________
  - ○ ផ្សេងៗ ________________________________________
- ❑ ថ្នាំសំឡាប់មេរោគ និងគ្រឿងផ្គត់ផ្គង់នានា សំរាប់និយោជិកទាំងអស់ អាចរកបានតាមទីតាំងនានា ដូចខាងក្រោម៖

  ________________________________________________________
- ❑ ទឹកលាងដៃសំឡាប់មេរោគមានប្រសិទ្ធិភាពប្រឆាំងជំងឺ COVID-19 សំរាប់និយោជិកទាំងអស់ អាចរកបានតាមទីតាំងនានា ដូចខាងក្រោម៖

  ________________________________________________________
- ❑ និយោជិកទាំងឡាយត្រូវបានរំលឹកអោយលាងដៃ អោយបានញឹកញាប់។
- ❑ ច្បាប់ចតចំលងនៃពិធីការនេះ ត្រូវបានចែកចាយដល់និយោជិកនីមួយៗ។
- ❑ តាមដែលអាចធ្វើទៅបាន កម្មករម្នាក់ៗ ត្រូវបានចាត់តាំងអោយនូវឧបករណ៍ផ្ទាល់ខ្លួន ហើយត្រូវបានគេណែនាំអោយជៀសវាងការចែករំលែកទូរស័ព្ទ, កុំព្យូទ័របន្ទះ ឬថេប្លេត, វិទ្យុពីរផ្លូវ, ឧបករណ៍ការងារផ្សេងៗ ទៀត, ឬឧបករណ៍ការិយាល័យ នៅកន្លែងណាដែលអាចធ្វើទៅបាន។ ផងដែរ ពួកគេក៏ត្រូវបានណែនាំមិនអោយចែករំលែក PPE ឡើយ។
- ❑ នៅកន្លែងដែលត្រូវចែករំលែករបស់របរនានា, ពួកគេត្រូវបានសំឡាប់មេរោគជាមួយឧបករណ៍សម្អាតដែលសមស្របសម្រាប់ផ្ទៃ រវាងការផ្លាស់ប្តូរវេន ឬការប្រើប្រាស់ណាមួយ ដែលញឹកញាប់ខ្លាំង, រួមបញ្ចូលនូវឧបករណ៍ដូចខាងក្រោមនេះ៖ ឧបករណ៍ការិយាល័យរួម, ដូចជាម៉ាស៊ីនថតចំលង, ម៉ាស៊ីនទូរសារ, ម៉ាស៊ីនព្រីនធ័រ, ក្តារចុច, ប្រដាប់កឹប, ប្រដាប់ដកគ្រាប់កឹប, ប្រដាប់បើកសំបុត្រ, ផ្ទៃនៅលើកន្លែងទទួលភ្ញៀវ, ស្ថានីយ៍ការងាររួម, ឧបករណ៍អូឌីយ៉ូស្តាប់ និងវីដេអូ, ឧបករណ៍ជជែកគ្នា ឬអេកូម។ល។
- ❑ ពេលវេលាត្រូវបានផ្តល់ជូននិយោជិតដើម្បីអនុវត្តនូវការអនុវត្តនូវការសំអាត ក្នុងអំឡុងពេលវេនរបស់ពួកគេ។ ការងារសំអាតត្រូវបានផ្តល់ឱ្យក្នុងម៉ោងធ្វើការ ដែលជាផ្នែកមួយនៃភារៈកិច្ចការងាររបស់និយោជិក។ កែប្រែម៉ោង, ប្រសិនបើចាំបាច់, ដើម្បីធានាអោយបាននូវការសម្អាតឱ្យបានទៀងទាត់ និងហ្មត់ចត់តាមភាពសមរម្យ។ ជម្រើសអោយមាននូវលទ្ធកម្មសម្រាប់ក្រុមហ៊ុន សំអាតនៃភាគីទីបី ដើម្បីជួយដល់តម្រូវការសំអាតដែលបានកើនឡើង, ទៅតាមតម្រូវការ។
- ❑ ត្រួតពិនិត្យអវត្តមានបុគ្គលិក និងមានបញ្ជីឈ្មោះបុគ្គលិកបំរុងដែលបានទទួលការបណ្តុះបណ្តាល នៅពេលដែលមាន។
- ❑ ពិចារណាដំឡើងម៉ាស៊ីនសម្អាតខ្យល់ដែលមានប្រសិទ្ធិភាពខ្ពស់ សម្រាប់ការិយាល័យ ឬកន្លែងធ្វើការផ្សេងៗ, ធ្វើឱ្យប្រសើរឡើងនូវតម្រងខ្យល់របស់អាគារ ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត តាមតែអាចធ្វើទៅបាន, និងធ្វើការកែប្រែផ្សេងទៀត ដើម្បីបង្កើនបរិ មាណខ្យល់ខាងក្រៅ និងខ្យល់នៅក្នុងការិយាល័យ និងកន្លែងផ្សេងទៀត។

- ❑ កែតម្រូវការប្រជុំបុគ្គលិកណាមួយ ដើម្បីធានានូវការឃ្លាតឆ្ងាយរាងកាយពីគ្នា និងប្រើប្រាស់ការប្រជុំបុគ្គលតូចៗ ដើម្បីរក្សា គោលការណ៍ឃ្លាតឆ្ងាយរាងកាយពីគ្នា។
- ❑ ធ្វើកិច្ចប្រជុំជាមួយកម្មករតាមទូរស័ព្ទ, តាមអ៊ិនធឺណែត, ឬនៅខាងក្រៅកន្លែង តាមដែលអាចធ្វើទៅបាន។ ពិចារណាការធ្វើសំភាសន៍ និងដាក់បញ្ចូលបុគ្គលិកថ្មីអោយមកធ្វើការតាមបែបនិម្មិត នៅពេលដែលអាចធ្វើទៅបាន។
- ❑ គោលនយោបាយទាំងអស់ ដែលបានពិពណ៌នានៅក្នុងបញ្ជីត្រួតពិនិត្យនេះ ក្រៅពីគោលការណ៍ទាក់ទងនឹងលក្ខ័ណ្ឌនៃការងារ ត្រូវបានអនុវត្តចំពោះបុគ្គលិកនៃការចែកចាយ ឬបញ្ជូន និងក្រុមហ៊ុនផ្សេងណាមួយទៀត ដែលអាចមាននៅក្នុងបរិវេណ ជាភាគី ទីបី។
- ❑ ស្រេចលើចិត្ត — ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត:

  ______________________________________________________________________________

## B. វិធានការណ៍នានា ដើម្បីធានាបាននូវគំលាតឆ្ងាយរាងកាយពីគ្នា

- ❑ អនុវត្តវិធានការណ៍នានា ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នាយ៉ាងហោចណាស់ ៦ ហ្វីត រវាង និងក្នុងចំណោមកម្មករ និងភ្ញៀវ។ នេះអាចរួមបញ្ចូលទាំងការដំឡើងរបាំងកញ្ចក់យាំង រវាងបុគ្គលិក និងភ្ញៀវនៅក្នុងហាង, កន្លែងកំសាន្ត, កន្លែងទទួលភ្ញៀវ ឬមជ្ឈមណ្ឌលអ្នកទស្សនា ឬដោយប្រើសញ្ញា/រូបភាពដែលមើលឃើញ ដើម្បីណែនាំអ្នកភ្ញៀវ អំពីទីកន្លែងដែលត្រូវឈរឬតំរង់ជួរ។ ភ្ញៀវគួរតែត្រូវបានណែនាំឱ្យទៅកាន់ទីកន្លែងដែលត្រូវឈរ, ដោយប្រើសំភារៈដែលមើលឃើញ និង/ឬ ពាក្យសំដីដែល សមរម្យ, នៅពេលដែលរង់ចាំប្រើស្ថានីយ៍ចាក់ទឹក, ស្ថានីយ៍ចាក់សំរាម RV ចោល, ស្ថានីយ៍ចាក់ប្រេងប្រូផេន និងទីតាំងសេវាកម្ម ស្រដៀងៗនេះ ផ្សេងៗទៀត។
- ❑ បុគ្គលិកត្រូវបានគេបញ្ចៀសដើម្បីចៀសវាងការចាប់ដៃគ្នាកណ្តាប់ដៃឬកែងដៃនិងទំនាក់ទំនងរាងកាយផ្សេងទៀត។
- ❑ ប្រតិបត្តិករ គួរតែត្រួតពិនិត្យតំបន់ដែលមនុស្សទំនងជាប្រមូលផ្តុំ និងធានាថាការឃ្លាតឆ្ងាយរាងកាយពីគ្នា និងការណែនាំផ្សេងទៀតត្រូវបានអនុវត្ត។ តំបន់ទាំងនេះអាចរួមបញ្ចូលទាំង តំបន់ហែលទឹក, វាលកីឡា, កន្លែងជិះស្គេត, ដើមផ្លូវលំ, តំបន់ប្រជាប្រិយដែលប្រើប្រាស់ប្រចាំថ្ងៃ, និងតំបន់ពិចនិច។ ដាក់សញ្ញាលើតម្រូវការចំងាយរាងកាយ។
- ❑ តំបន់ខាងក្រោមអាចនៅតែបើក សម្រាប់ការប្រើប្រាស់សំរាប់សមាជិកគ្រួសាររបស់ខ្ញុំតែមួយគត់ប៉ុណ្ណោះ: បាល់បោះ, វាយកូនបាល់តិន្នីស និងទីលានបាល់ទះ។ រចនាសម្ព័ន្ធសំរាប់ឡើងខាងក្នុង និងសួនកុមារលេងកំសាន្ត នៅតែត្រូវបិទ។ រចនាសម្ព័ន្ធសំរាប់ឡើង និងទីធ្លាកំសាន្តអាចបើក តាមការសំរេចចិត្តរបស់ប្រតិបត្តិករ និងស្របតាមការណែនាំរបស់រដ្ឋ ដែលមាន ឬរកឃើញ [នៅទីនេះ។]
- ❑ សម្រាប់កន្លែងដែលផ្តល់សេវាកម្មសកម្មភាពក្រៅផ្ទះ ដែលបង់ប្រាក់ និងក្រោមការគ្រប់គ្រង, សូមពិចារណាអនុវត្តនូវប្រព័ន្ធកក់ទុកជាមុន ដើម្បីកំណត់ចំនួនភ្ញៀវនៅទីតាំងនោះ។

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

- ❑ ពិចារណាអនុវត្តជម្រើសឆែកឆេរពីចម្ងាយ សម្រាប់ការមកដល់ថ្មីនៅឯទីលានជំរុំ ឬសួនឧទ្យាន RV នៅកន្លែងណា ដែលអាចធ្វើ បាន។ ដាក់ស្លាកសញ្ញានៅច្រកចូលរបស់សួនឧទ្យាន ដើម្បីទំនាក់ទំនងជាមួយភ្ញៀវ អំពីអ្វីដែលពួកគេត្រូវធ្វើ នៅពេលមកដល់។ រាយលេខទូរស័ព្ទ, ឧទាហរណ៍, សម្រាប់អ្នកទស្សនាដើម្បីធ្វើការទាក់ទង ជាជាងចូលទៅកាន់តំបន់ចុះឈ្មោះ។ លើកទឹកចិត្តអោយប្រើការទូទាត់តាមអ៊ិនធឺរណែត, ស្ថានីយ៍បង់ប្រាក់នៅនឹងកន្លែង, ការទូទាត់តាមកាតឥណទាន, ឬការទូទាត់តាមទូរស័ព្ទ, នៅកន្លែងណាដែល អាចធ្វើទៅបាន។

- ❑ ប្រសិនបើការឆែកឆេរពីចម្ងាយមិនអាចធ្វើទៅបាននោះទេ, សូមឆែក ឬពិនិត្យភ្ញៀវនៅខាងក្រៅ, ប្រសិនបើអាច, និងផ្តល់វិក័យ ប័ត្រតាមអ៊ីម៉ែល។ នៅពេលចាំបាច់, អមទៅជាមួយ ឬណែនាំអ្នកទស្សនាដោយផ្ទាល់ អោយទៅកាន់ទីកន្លែងរបស់ពួកគេនៅ ពេលដែលពួកគេមកដល់ ស្របតាមតម្រូវការឃ្លាតឆ្ងាយរាងកាយពីគ្នា។ មានតែគ្រួសារមួយប៉ុណ្ណោះ ដែលអាចកាន់កាប់កន្លែង បោះតង់ ឬបន្ទប់ជួលនីមួយៗ និងភ្ញៀវដែលមិនទាន់បានចុះឈ្មោះ មិនគួរត្រូវបានអនុញ្ញាតិឱ្យចូលទៅកន្លែងបោះជំរុំ ឬសួន ឧទ្យាន RV ឡើយ។

- ❑ ពិចារណាអនុវត្តដំណើរការសម្រាប់អ្នកទស្សនា ដើម្បីទិញទំនិញដែលបានទិញទុកមុនពីហាងទូទៅ, រួមមានអុសដុត, អីវ៉ាន់ម្ហូបអាហារ ឬទំនិញផ្សេងទៀត, ហើយឱ្យបុគ្គលិកដឹកជញ្ជូនទំនិញទៅកាន់កន្លែងបោះជំរុំ ឬ RV របស់អ្នកទេសចរណ៍។

- ❑ ទីធ្លាខាងក្រៅមានគោលបំណងសម្រាប់ការប្រមូលផ្តុំ និងការធ្វើសកម្មភាពជាក្រុម, រួមមានទីធ្លារហោណាំង, ភ្លើងរង្វង់មូល, ផ្ទះបាយកន្លែងបោះជំរុំសំរាប់ការប្រើប្រាស់ជាសាធារណៈ និងរង្គមណ្ឌលគួរតែត្រូវនៅតែបិទ។ ដកចេញ, ញែកចេញ, បិទផ្លាកបិទ ឬបិទបង់ស្អីតតាមកៅអីអង្គុយទាំងអស់, តុពិចនិចតំបន់រួម, និងកន្លែងអង្គុយដែលមានមនុស្សច្រើននាក់ (រួមទាំងកន្លែងអង្គុយ ជុំវិញរណ្តៅភ្លើង) ដើម្បីទំលាក់ទឹកចិត្ត កុំអោយភ្ញៀវទេសចរណ៍មកប្រមូលផ្តុំ ឬជួបជុំគ្នា។

- ❑ រាល់ព្រឹត្តិការណ៍សាធារណៈ និង/ឬការប្រមូលផ្តុំដែលរួមដែលមានមនុស្សច្រើន រួមមាន ក្រុមដុតភ្លើង, ក្រុមបោះជំរុំ, ក្រុមធ្វើបទបង្ហាញនៅឯរង្គមណ្ឌល, ក្រៅឆាកតន្ត្រី ឬការសម្តែងនានា ឬព្រឹត្តិការណ៍ផ្សេងទៀត ត្រូវតែលុបចោល ឬពន្យារពេល។

- ❑ ជម្រកពិចនិចតូចៗ, ដូចជាកន្លែងដែលមានតែក្រុមគ្រួសារប៉ុណ្ណោះ, អាចនៅបើក ដោយមានការបិទសញ្ញាអំពីការរឹតត្បិត ទាក់ទងនឹងការឃ្លាតឆ្ងាយរាងកាយពីគ្នា (ឧទាហរណ៍., កំរឹតនូវការប្រើប្រាស់ ចំពោះតែគ្រួសារមួយប៉ុណ្ណោះ ក្នុងពេលម្តងៗ)។

- ❑ វាយតំលៃកន្លែងបោះជំរុំ និងសួនឧទ្យាន RV ដើម្បីកំណត់ថាតើសួនឧទ្យាននេះ ត្រូវការប្រតិបត្តិការ ដែលមានសមត្ថភាពកាត់បន្ថយចុះ ដើម្បីរក្សានូវការឃ្លាតឆ្ងាយរាងកាយពីគ្នា។

## សកម្មភាពខាងក្រៅផ្ទះ

- ❑ ប្រតិបត្តិករគួរតែចាត់វិធានការណ៍ ដើម្បីធានាថាសកម្មភាពហានិភ័យខ្ពស់, រួមទាំងសកម្មភាពដែលមិនទាន់ត្រូវបានណែនាំដោយគោលការណ៍ណែនាំរបស់រដ្ឋ, មិនត្រូវបានកើតឡើងទៅលើទ្រព្យសម្បត្តិ ឬកន្លែងរបស់ពួកគេ។

- ❑ វាយតំលៃដំណើរការនៃការជួល និងការអោយខ្ចីនូវឧបករណ៍កំសាន្ត និងកំណត់ថា តើមានសមត្ថភាពបុគ្គលិកគ្រប់គ្រាន់ និង មានសំភារៈសំអាត និងសំឡាប់មេរោគគ្រប់គ្រាន់ ដើម្បីបើកប្រតិបត្តិការបែបនេះឡើងវិញ ឬអត់។ ការជួលត្រូវតែគោរពតាមពិធីការសេ

វាកម្មជួលឧបករណ៍ក្រៅផ្ទះ (ឧបសម្ព័ន្ធ D)។

- ផ្លាស់ប្តូរសកម្មភាពកំសាន្តក្រៅផ្ទះនានា, នៅកន្លែងណាដែលចាំបាច់, ដើម្បីធានាបាននូវពិធីការលាងសំអាត និងការសំឡាប់ មេរោគ បានយ៉ាងត្រឹមត្រូវ។
- ការលាងសំអាត និងសំឡាប់មេរោគ "ទំនិញទន់ៗ" ដូចជា អាវសង្គ្រោះជីវិត, អាវទឹកសើម, ខ្សែពួរកប្បាស, កាបូបកែប, ឬកាបូបស្ពាយខ្នង, ដាក់ចេញនូវបញ្ហាប្រឈមជាច្រើន។ គ្រឿងបរិក្ខារបែបនេះ តម្រូវឱ្យមាននីតិវិធីសំអាត ដែលមានប្រសិទ្ធិភាព ឬធ្វើ បញ្ជីសារពើភណ្ឌឧបករណ៍គ្រប់គ្រាន់ ដើម្បីអនុញ្ញាតិឱ្យមាន "ពេលវេលាមិនត្រូវប្រើ" អោយបានគ្រប់គ្រាន់ យ៉ាងហោចណាស់ បីថ្ងៃ រវាងការប្រើប្រាស់ ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺ COVID-19។
- កម្មវិធី និងកីឡាដែលមានការប៉ះពាល់ ឬទំនាក់ទំនងខ្ពស់ ដែលតម្រូវឱ្យមានទំនាក់ទំនងជិតស្និទ្ធ តិចជាងប្រាំមួយហ្វីតរវាងសមាជិកនៃគ្រួសារផ្សេងគ្នា គួរតែត្រូវបានផ្អាក។ នេះរួមបញ្ចូលទាំងសកម្មភាពនានា ដូចជាព្រឹត្តិការណ៍កីឡាជាក្រុម, ការរើសបាល់បោះ, សកម្មភាពកីឡាចម្រុះ, ការរត់ប្រណាំង ឬរាំ។
- កំណត់សកម្មភាពកំសាន្តក្រៅផ្ទះដែលមានការប៉ះពាល់ ឬទំនាក់ទំនងជិតស្និទ្ធ ចំពោះអង្គភាពក្រុមគ្រួសារ។ នេះរួមបញ្ចូលទាំងការលទូក, វគ្គខ្សែពួរ និងទ្បើងជញ្ជាំង។ នៅទីធ្លាបោះជំរុំ និងសួនឧទ្យាន RV, សូមពិចារណាថាតើការដើរគយគន់ធម្មជាតិ, រាត្រីភាពយន្ត, វាយកូនហ្គោលខ្នាតតូច, ការធ្វើទីតាំងភូមិសាស្ត្រ, ការប្រមាញ់អេតចាយ ឬសកម្មភាពផ្សេងៗទៀត អាចត្រូវបាន បង្កើតឡើង សម្រាប់អង្គភាពគ្រួសារតាមរបៀបមួយដែលរក្សានូវការឃ្លាតឆ្ងាយរាងកាយពីគ្នា។
- នៅពេលស្លៀកសំលៀកបំពាក់អោយមនុស្សដែលត្រូវពាក់មួកសុវត្ថិភាព, ឧបករណ៍, សម្លៀកបំពាក់ការពារ, អាវសង្គ្រោះជីវិត, ឬរបស់របរផ្សេងៗ បុគ្គលិកត្រូវរក្សានូវការឃ្លាតឆ្ងាយរាងកាយពីគ្នា។ ពេលណាដែល អាចធ្វើទៅបាន, បុគ្គលិកគួរបង្ហាញអំពីរបៀបពាក់ និងដោះចេញនូវដកឧបករណ៍ឱ្យបានត្រឹម ត្រូវជាជាងការញែកចេញ ឬបំបែកនូវចម្ងាយរាងកាយពីគ្នា ដើម្បីជួយ។

### បន្ទប់ទឹករួម និងកន្លែងក្បាលផ្កាឈូកងូតទឹករួម

- បន្ទប់ទឹកសាធារណៈ គួរតែត្រូវបានសម្អាត និងសំឡាប់មេរោគពេញមួយថ្ងៃ។ ចំនួនមនុស្ស អតិបរិមាសម្រាប់កន្លែងបោះជំរុំ, សួនឧទ្យាន RV, ឬតំបន់កំសាន្ត គួរតែត្រូវផ្អែកលើចំនួននៃបន្ទប់ទឹក ដែលមានដំណើរការ ពេញលេញ ដែលប្រតិបត្តិករសួនឧទ្យានអាចថែទាំបាន ហើយដែលអាចគាំទ្រដល់តម្រូវការនៃគំលាតឆ្ងាយរាងកាយពីគ្នា។
- កន្លែងបន្ទប់ទឹកសម្រាប់ចែករំលែក គួរតែត្រូវបានសម្អាតឱ្យបានទៀងទាត់ដោយប្រើថ្នាំសម្លាប់មេរោគ ដែលបានចុះឈ្មោះជាមួយ EPA ពេញមួយថ្ងៃ។ ផ្ទៃដែលប៉ះពាល់ខ្ពស់ ដូចជាក្បាលម៉ាស៊ីន ឬក្បាលរ៉ូប៊ីណេទឹក, បង្គន់, ប្រដាប់កាន់ ឬមូលតាមទ្វារ, ឧប ករណ៍ប្តូរភ្លើង/ពន្លឺ ត្រូវតែសម្អាត និងសំឡាប់មេរោគអោយបានញឹកញាប់។ និយោជិកគួរតែទទួលបានការបណ្តុះបណ្តាលអំពី គ្រោះថ្នាក់ និងការប្រើប្រាស់ផលិតផលថ្មីអោយបានត្រឹមត្រូវ តាមតម្រូវការ Ca/OSHA និងត្រូវបានផ្តល់ជូននូវឧបករណ៍ការពារចាំបាច់ សម្រាប់ផលិតផលសំអាតជាក់លាក់ ដែលកំពុងប្រើប្រាស់, ដូចជា ការការពារភ្នែក ឬស្រោមដៃ។
- បង្កើត និងបិទប្រកាសកាលវិភាគការធ្វើសម្អាត នៅគ្រប់កន្លែងបន្ទប់ទឹកដែលបើកដំណើរការ។ បិទកាលវិភាគសម្អាតនៅលើមាត់

ទ្វារ ដើម្បីអោយអ្នកទេសចរណ៍ដឹងថា ពេលណាពួកគេ អាច/មិនអាចប្រើប្រាស់បន្ទប់ទឹកបាន។ ត្រូវប្រាកដថា ត្រូវបិទបន្ទប់ទឹកក្នុងកំឡុងពេលដំណើរការសំអាត និងសំឡាប់មេរោគ។

- ❑ ពិចារណាប្រើបញ្ជីត្រួតពិនិត្យ ឬប្រព័ន្ធសវនកម្ម ដើម្បីតាមដាន ថាតើការសម្អាតត្រូវបានធ្វើឡើងញឹកញាប់ប៉ុណ្ណា។
- ❑ អនុញ្ញាតិអោយប្រើបន្ទប់ទឹកផ្កាឈូកតែប៉ុណ្ណោះ ប្រសិនបើមានការខ័ណ្ឌចែកមានដាក់ដំឡើង នៅនឹងកន្លែង ឬសញ្ញាត្រូវបានគេបិទផ្សាយ ដើម្បីបញ្ជាក់ពីតម្រូវការ នៃការឃ្លាតឆ្ងាយរាងកាយពីគ្នា។ ប្រសិនបើការខ័ណ្ឌចែក ឬចម្ងាយឆ្ងាយត្រឹមត្រូវ មិនអាចធ្វើបានទេ កន្លែងទាំងនេះ គួរតែនៅតែបិទ។
- ❑ ធានាថាគ្រឿងបរិក្ខារអនាម័យ នៅតែដំណើរការ ហើយត្រូវបានស្តុកទុកជាបន្តបន្ទាប់គ្រប់ពេលវេលាទាំងអស់។ ផ្តល់សាប៊ូ, ក្រដាស់ជូត, និងទឹកធ្វើអនាម័យដែលបន្ថែមទៀត នៅពេលដែលមានតំរូវការ។ ដំឡើងឧបករណ៍ដែលមិនប្រើដៃ, បើអាចធ្វើទៅ បាន, រួមទាំងឧបករណ៍ចាប់សញ្ញាដោយប្រើចលនាធុងស្នូកទឹក, ក្បាលរ៉ូប៊ីណេ, ឧបករណ៍បញ្ចេញសាប៊ូ, ឧបករណ៍បញ្ចេញទឹក ធ្វើអនាម័យដៃ និងឧបករណ៍បញ្ចេញក្រដាស់ជូត។
- ❑ ទ្វារទៅកាន់បន្ទប់ពហុកន្លែង គួរតែអាចបើក និងបិទបាន ដោយមិនចាំបាច់ប៉ះដៃនោះឡើយ។ ប្រសិនបើទ្វារមិនអាចត្រូវបានបើកដោយមិនប៉ះដៃ ឬអ្នកបើកទ្វារដោយប្រើដៃ, រុញទ្វារអោយបើក និង/ឬដាក់បង្កាន់ដៃសំរាមនៅមាត់ទ្វារ ដើម្បីធានាថា ក្រដាស់ជូតអាចត្រូវបានគេបោះចោល យ៉ាងងាយស្រួលនៅពេលប្រតិបត្តការទ្វារ។ ទីតាំង និងការរៀបចំនូវកន្លែងទទួល ឬទុកដាក់កាកសំណល់ មិនគួរជ្រៀតជ្រែកឬរំខានដល់ផ្លូវចេញ, ការជម្លៀសចេញ, ឧបករណ៍សង្គ្រោះបន្ទាន់, ឬការសំរបសំរួលដ៏មានហេតុផលណាមួយ ដែលបានផ្តល់ជូន ក្រោមច្បាប់ស្តីពីជនដែលរស់នៅជាមួយពិការភាពអាមេរិកាំង (Americans with Disabilities Act)។ ត្រូវប្រាកដថា ធុងសំរាមត្រូវបានចាក់ចោលយ៉ាងទៀងទាត់។
- ❑ កន្លែងបោះជំរុំ, សួនឧទ្យាន RV, និងភ្ញៀវទេសចរណ៍កំសាន្តស្បាយក្រៅផ្ទះ គួរតែត្រូវបានណែនាំថាធុងស្នូកទឹក អាចជាប្រភពនៃការបង្ករឬចំឡងរោគ ហើយគួរចៀសវាងកុំដាក់ច្រាសដុសធ្មេញ និងរបស់របរផ្សេងៗទៀតដោយផ្ទាល់ ទៅលើផ្ទៃបញ្ជរ។ កន្ត្រកផងដែរ ក៏អាចត្រូវបានប្រើសម្រាប់របស់របរផ្ទាល់ខ្លួន ដើម្បីកំរឹតនូវការប៉ះពាល់របស់ពួកវា ជាមួយផ្ទៃផ្សេងទៀតនៅក្នុងបន្ទប់ទឹក។
- ❑ ការគ្រប់គ្រងកន្លែងបោះជំរុំ និងសួនកម្សាន្ត RV គួរតែលើកទឹកចិត្តអោយភ្ញៀវទេសចរណ៍ស្នាក់នៅក្នុងយានយន្ត ដែលមានបង្គន់ និងក្បាលផ្កាឈូកទឹក/ឧបករណ៍ងូតទឹក ដើម្បីប្រើប្រាស់នូវគ្រឿងបរិក្ខារផ្ទាល់ខ្លួនរបស់ពួកគេផ្ទាល់ ជាជាងរបស់របរ ឬកន្លែងចែករំលែក, ប្រសិនបើអាចធ្វើទៅបាន។
- ❑ ផ្តល់ព័ត៌មានអំពីរបៀបលាងដៃអោយបានត្រឹមត្រូវ, រួមទាំងព្យួរនូវផ្លាកសញ្ញា នៅក្នុងបន្ទប់ទឹក។

**អាងហែលទឹក និងកន្លែងអក្វាទិច (កន្លែងមាន, ក្នុង ឬលើទឹក)**

- ❑ សូណា, បន្ទប់ចំហាយទឹក, និងអាងទឹកក្តៅ គួរតែត្រូវនៅបន្តបិទ។
- ❑ រក្សាកម្រិតសម្លាប់មេរោគអោយបានត្រឹមត្រូវ (១-១០ ផ្នែក ក្នុង ១ លានដែលគ្មានក្លរីន ឬ ៣-៨ ភីភីអឹមប្រូមីន) និងភីអេហ្ច pH (៧.២-៨)។

❑ ពិគ្រោះយោបល់ជាមួយក្រុមហ៊ុន ឬវិស្វករដែលបានរចនា ឬរៀបចំកន្លែងអក្វាទិច ដើម្បីសំរេចថាតើថ្នាំសម្លាប់មេរោគ ដែលត្រូវបានអនុម័តដោយ EPA គឺប្រសើរបំផុតសម្រាប់កន្លែងអក្វាទិច។ ធានាអោយមានការប្រើប្រាស់ដោយសុវត្ថិភាព និងត្រឹមត្រូវ និងរក្សា ទុកនូវថ្នាំសំលាប់មេរោគទាំងឡាយ, រួមទាំងរក្សាទុកនូវផលិតផល អោយមានសុវត្ថិភាពនៅឆ្ងាយពីកុមារ។

❑ រៀបចំប្រព័ន្ធ ដើម្បីអោយគ្រឿងសង្ហារឹម និងគ្រឿងបរិក្ខារ (ឧទាហរណ៍., កៅអី នៅកន្លែងសំរាក) ដែលត្រូវការនូវការសម្អាត និង សំឡាប់មេរោគ ត្រូវបានទុកដាក់នៅដោយឡែក ពីគ្រឿងសង្ហារឹមដែលបានសម្អាតរួច និងរម្ងាប់មេរោគរួចរាល់ហើយ។ ត្រូវដាក់ស្លាកសញ្ញា ចំពោះធុងដាក់ឧបករណ៍ដែលបានប្រើប្រាស់រួច ដែលមិនទាន់បានសម្អាត និងរម្ងាប់មេរោគរួច និងធុងសម្រាប់ឧបករណ៍ដែលបានសម្អាត និងសំឡាប់មេរោគរួចរាល់ហើយ។

❑ លើកទឹកចិត្តភ្ញៀវទេសចរណ៍អោយយកមកជាមួយ និងប្រើកន្សែងផ្ទាល់ខ្លួនរបស់ពួកគេ។ ប្រសិនបើកន្សែងត្រូវបានផ្តល់អោយ, សូមបោកគក់ពួកគេ និងសម្លៀកបំពាក់ យោងទៅតាមការណែនាំរបស់អ្នកផលិត។ ប្រើសីតុណ្ហភាពទឹកដែលសមស្របបំផុត និងសំងួតរបស់របរទាំងអស់នោះ អោយបានស្ងួតទាំងស្រុង។ កាន់កន្សែងដោយប្រើស្រោមដៃ ដែលអាចចោលបាន និងមានការរំខានតិចតួចបំផុត, ដូចជា., កុំអ្រងួនពួកគេ។

❑ លើកទឹកចិត្តមនុស្សពីការចែករំលែករបស់របរ, ជាពិសេសរបស់របរដែលពិបាកក្នុងការសម្អាត និងសំឡាប់មេរោគ ឬរបស់របរដែលនឹងក្លាយមកជា ឬនឹងមានការប៉ះពាល់ជាមួយមុខ (ឧទាហរណ៍., វ៉ែនតាការពារភ្នែក, តំបៀតខ្ទាស់ច្រមុះ និងបំពង់ដកខ្យល់របស់អ្នកមុជទឹក)។

❑ ធានាថាកន្លែងនេះ មានឧបករណ៍គ្រប់គ្រាន់សម្រាប់អ្នកឧបត្ថម្ភ, ដូចជា ក្តារទាត់, ក្បាលអាងហែលទឹក និងឧបករណ៍អណ្តែត ផ្សេងទៀត, ដើម្បីកាត់បន្ថយការចែករំលែកអោយនៅតិចបំផុត នៅពេលដែលអាចធ្វើទៅបាន។ កំណត់ការប្រើប្រាស់គ្រឿងបរិក្ខារអោយតែភ្ញៀវមួយក្នុងពេលតែមួយ ហើយសម្អាត និងសំឡាប់មេរោគរបស់របរទាំងនោះ បន្ទាប់ពីប្រើប្រាស់រួចម្តងៗ។

❑ សម្រាប់កន្លែងលេងទឹកក្នុងអាគារ, ណែនាំ និងចរាចរខ្យល់មកពីខាងក្រៅតាមដែលអាចធ្វើទៅបាន ដោយបើកបង្អួច និងទ្វារ ដោយប្រើកង្ហារ ឬវិធីសាស្ត្រផ្សេងៗទៀត។ ទោះយ៉ាងណាក៏ដោយ, កុំបើកបង្អួច និងទ្វារ ប្រសិនបើការធ្វើបែបនេះ បង្កហានិភ័យសុវត្ថិភាពដល់បុគ្គលិក ភ្ញៀវទេសចរណ៍ ឬអ្នកហែលទឹក។

❑ ផ្លាស់ប្តូរប្លង់នាវា ឬទីកន្លែងលេង និងតំបន់ផ្សេងទៀត ដែលនៅជុំវិញអាងទឹក ដើម្បីធានាថា កន្លែងឈរ និងកន្លែងអង្គុយ អាចគាំទ្រដល់តំរូវការនៃការឃ្លាតឆ្ងាយរាងកាយពីគ្នា។ នេះអាចរាប់បញ្ចូលទាំង ការដកកៅអីកន្លែងអង្គុយសំរាកចេញ ឬរុំព័ទ្ធ/បិទកន្លែង ដើម្បីទំលាក់ទឹកចិត្តក្នុងការប្រើប្រាស់។

❑ ផ្តល់ជូននូវសញ្ញារាងកាយ ឬមគ្គុទេសក៍ផ្លូវ (ឧទាហរណ៍., ខ្សែផ្លូវនៅក្នុងទឹក ឬកៅអី និងតុនៅលើដំបូល ឬជាន់) និងសញ្ញាមើលឃើញ (ឧទាហរណ៍., បិទបង់ស្អិតនៅលើដំបូល ឬជាន់ ឬចិញ្ចើមផ្លូវ) និងសញ្ញាដើម្បីធានាថា បុគ្គលិក, ភ្ញៀវទេសចរណ៍ និងអ្នកហែលទឹក នៅយ៉ាងហោចណាស់ចំងាយប្រាំមួយហ្វីត ពីគ្នាទៅវិញទៅមក, ទាំងនៅក្នុង និងក្រៅទឹក។

❑ តាមដែលអាចធ្វើទៅបាន, ដំឡើងរបាំងរាងកាយ ដែលមិនជ្រាបទឹក ដូចជាកញ្ចក់របាំង ដែលបុគ្គលិក និងអ្នកភ្ញៀវឬអ្នកឧបត្ថម្ភ ត្រូវតែធ្វើអន្តរកម្ម, ហើយការឃ្លាតឆ្ងាយ រាងកាយពីគ្នា គឺមានការពិបាក។

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

- ❑ ពិចារណាអនុវត្តន៍ការកក់ជាមុន សំរាប់ការប្រើប្រាស់អាងហែលទឹក ឬអនុវត្តនូវយន្តការផ្សេងទៀត ដើម្បីគាំទ្រដល់ការឃ្លាតឆ្ងាយ រាងកាយពីគ្នា។ នេះអាចរួមបញ្ចូលទាំង ការកក់ឡេន ឬផ្លូវពេញ សម្រាប់ការហែលជុំម្នាក់ៗ។
- ❑ ធានាថា អ្នកយាមការពារជីវិតទាំងឡាយ ដែលកំពុងយាមការពារជីវិតយ៉ាងសកម្ម ក៏មិនត្រូវបានគេរំពឹងថា នឹងតាមដានការលាង ដៃ , ការប្រើប្រាស់គំរបមុខក្រណាត់ ឬការឃ្លាតឆ្ងាយ រាងកាយពីគ្នាផងដែរនោះឡើយ។ ប្រគល់ការទទួលខុសត្រូវលើការត្រួតពិនិត្យ នេះ ដល់បុគ្គលិកម្នាក់ទៀត។
- ❑ កន្លែងអង្គុយទិច គួរតែចៀសវាងសកម្មភាពដែលលើកកំពស់ ដល់ការប្រមូលផ្តុំជាក្រុម។

**កាប៊ីន ឬផ្ទះតូចៗ និងយូនីតជួល**

- ❑ កន្លែងបោះជំរុំ និងសួនកម្សាន្ត RV ដែលមានកាប៊ីន ឬយូនីតជួលផ្សេងទៀត គួរតែចាត់វិធានការណ៍ត្រឹមត្រូវ ដើម្បីសម្អាត និង សំឡាប់ មេរោគ នៅតំបន់ទាំងនោះ បន្ទាប់ពីការប្រើប្រាស់នីមួយៗរួច។ នេះរាប់បញ្ចូលទាំង ការជូត និងសំអាតនូវកំរាលគ្រែ, តុ, តេលេទូរទស្សន៍, ក្បាលគ្រែ, ក្បាល ឬលើតុ, ឧបករណ៍ផ្ទះបាយ, ដៃទូរទឹកកក, ដៃមួលចង្ក្រាន, កញ្ចក់ និងរបស់របរផ្សេងៗទៀត។
- ❑ កំរាលពូក និងស្រោមខ្នើយទាំងអស់ ត្រូវតែត្រូវបានយកចេញ និងបោកគក់ រវាងការស្នាក់នៅរបស់ភ្ញៀវនីមួយៗ, រួមទាំងរបស់របរដែលមើលទៅ ដូចជាមិនទាន់ត្រូវបានប្រើ។ នៅពេលសម្អាតពូក, កន្សែង, ឬរបស់របរបោកគក់ផ្សេងទៀត នៅក្នុងយូនីតជួលទាំងឡាយ, ត្រូវធានាថា បុគ្គលិកពាក់ស្រោមដៃដែលអាចចោលបាន នៅពេលដែលធ្វើការ បោកគក់របស់កខ្វក់ ហើយបន្ទាប់មកបោះចោល បន្ទាប់ពីប្រើរួចម្តងៗ។ លាងដៃជាមួយសាប៊ូ ឬធ្វើអនាម័យដៃភ្លាមៗ បន្ទាប់ពីស្រោមដៃត្រូវបានដោះចេញ។ កុំទុក កំរាលពូក និងស្រោមខ្នើយបន្ថែមទៀត នៅក្នុងយូនីតជួល។ ផ្តល់ជូននូវរបស់របរទាំងអស់នេះ ទៅតាមការស្នើសុំតែប៉ុណ្ណោះ។

- ❑ កុំអង្រួន ឬពូតការបោកគក់កខ្វក់។ នេះនឹងកាត់បន្ថយលទ្ធភាពនៃការធ្វើអោយបែកខ្ញែក ឬបំបែកវីរុស តាមរយៈខ្យល់។ បោកគក់របស់របរទាំងឡាយ ស្របទៅតាមការណែនាំរបស់អ្នកផលិត។ ប្រសិនបើអាចធ្វើទៅបាន, បោកគក់របស់របរទាំងឡាយ ដោយប្រើការដាក់ ឬរៀបចំប្រើនូវទឹកក្តៅឧណ្ហៗសមស្របបំផុត សម្រាប់របស់របរទាំងឡាយ និងធ្វើការសំងួតអោយស្ងួតទាំងស្រុង។ សំអាត និងសំឡាប់មេរោគដល់កន្ត្រក ឬល្អីសំរាប់ដាក់របស់របរបោកគក់ យោងតាមការណែនាំខាងលើ សម្រាប់ផ្ទៃ។ ប្រសិនបើអាចធ្វើទៅបាន, បានសូមពិចារណាដាក់ទ្រនាប់ចង់មួយ ដែលអាចទាំងចោលបាន ហើយនឹងបោះចោល បន្ទាប់ពីប្រើប្រាស់រួច ម្តងៗ ឬអាចបោកគក់បាន បន្ទាប់ពីប្រើប្រាស់ម្តងៗ។
- ❑ របស់របរផ្ទះបាយ, រួមទាំងឆ្នាំង, ខ្ទះ និងប្រដាប់ប្រដាប្រើប្រាស់, ត្រូវតែលាងសម្អាតយ៉ាងហ្មត់ចត់ជាមួយសាប៊ូ និងទឹកក្តៅឧណ្ហៗ នៅក្នុងម៉ាស៊ីនលាងចាន, រវាងភ្ញៀវស្នាក់នៅម្នាក់ៗ ឬម្តងៗ។ ផ្តល់សាប៊ូលាងចានអោយបានគ្រប់គ្រាន់ និងអេប៉ុងថ្មីដែលមិនបានប្រើ សម្រាប់ភ្ញៀវម្នាក់ៗនៅពេលមកដល់។ ពិចារណាពីការជំនួសប្រដាប់ប្រដាប្រើប្រាស់ ជាមួយនឹងឧបករណ៍ឬប្រដាប់ប្រដាធ្វើម្ហូប ឬបរិភោគអាហារតែមួយពេល ឬតែម្តងគត់, ប្រសិនបើអាច។
- ❑ ពិចារណាបង្កើតរយៈពេលរង់ចាំចំនួន ២៤ ម៉ោង បន្ទាប់ពីភ្ញៀវ ពិនិត្យចាកចេញរួច មុនពេលសម្អាតកន្លែងស្នាក់នៅដែលគ្រប់គ្រងដោយ កន្លែងបោះជំរុំ, រួមទាំងយូនីតជួល។

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

- ❑ យូនីតជួលណាមួយ ដែលមានបំណងធ្វើនូវការប្រមូលផ្តុំធំៗ, រួមទាំងសន្និសិទ ឬការប្រជុំនានា, មិនគួរត្រូវបានបើកទេ រហូតដល់ប្រតិបត្តិការបែបនេះ អាចចាប់ផ្តើមឡើងវិញ។

## អាហារ និងការបរិភោគ

- ❑ អនុវត្តតាម ពិធីការរបស់មន្ត្រីសុខភាពទីក្រុងឡុងប៊ិច ទាក់ទងនឹងភោជនីយដ្ឋាន សម្រាប់ការណែនាំដែលទាក់ទងនឹងអាហារ និងការបរិភោគ។
- ❑ ប្រតិបត្តិករកំសាន្តសប្បាយក្រៅផ្ទះ មិនគួរធ្វើផតឡាក់ ឬព្រឹត្តិការណ៍បរិភោគ និងការផឹកស៊ីលក្ខណៈគ្រួសារស្រដៀងគ្នា ដែលបង្កើននូវហានិភ័យ នៃការឆ្លង។ ប្រសិនបើម្ហូបអាហារ និងភេសជ្ជៈបានត្រូវបម្រើ ឬចែករំលែក, ផ្តល់នូវរបស់របរដែលបំរើក្នុងពេលតែម្តងគត់, ធុងបោះចោល នៅពេលណាដែលអាចធ្វើទៅបាន។ បុគ្គលិកឬអ្នកស្ម័គ្រចិត្តដែលកំពុងបម្រើអាហារគួរតែលាងដៃ អោយបានញឹកញាប់ និងពាក់ស្រោមដៃ ដែលអាចចោលបាន និងពាក់គំរបមុខ។

## កន្លែងបោកគក់

- ❑ ប្រសិនបើចាំបាច់, លៃតម្រូវម៉ោងប្រតិបត្តិការសម្រាប់កន្លែង បន្ទប់បោកគក់ ដើម្បីធានាថា បុគ្គលិកមានពេលវេលាគ្រប់គ្រាន់ ក្នុងការសម្អាត និងសំឡាប់មេរោគលើគំរប និងទ្វារម៉ាស៊ីនបោកគក់, កញ្ចក់ធ្នឹម, លើតុនិងខោនធើ, កៅអី ឬកៅអីអង្គុយវែង, ម៉ាស៊ីនចែកចាយសាប៊ូ, ម៉ាស៊ីនលក់, ម៉ាស៊ីនផ្លាស់ប្តូរ, ស្ទូកធុងទឹក និងតំបន់ផ្សេងៗទៀត។

- ❑ ពិចារណាដាក់ទឹកធ្វើអនាម័យដៃ និងក្រដាស់សំឡាប់មេរោគ នៅក្នុងបន្ទប់បោកគក់ ដើម្បីអោយភ្ញៀវ អាចជូតសំអាតកន្លែងនោះ មុន/ក្រោយ ពេលពួកគេប្រើម៉ាស៊ីនរួច។
- ❑ ដកចេញនូវរាល់ហ្គេម, សៀវភៅ, ខិត្តប័ណ្ណ ឬរបស់របរផ្សេងទៀត ចេញពីកន្លែងបោកគក់។ ដកចេញនូវកន្ត្រកបោកខោអាវ ឬយកធុងចេញ, ប្រសិនបើមាន។
- ❑ ពិចារណាបង្កើតនូវប្រព័ន្ធប្រភេទណាត់ជួប សំរាប់កន្លែងបោកគក់ ដើម្បីអោយបុគ្គលិកដឹងថា ពេលណាកន្លែងប្រើប្រាស់កំពុង ត្រូវបានប្រើប្រាស់ ហើយភ្ញៀវអាចចៀសវាងអន្តរកម្មដែលមិនចាំបាច់។ ចាក់សោរកន្លែងបោកគក់ នៅចន្លោះពេលដែលបានធ្វើការណាត់ជួប ដើម្បីធានាអោយបាននូវពេលវេលាគ្រប់គ្រាន់ សម្រាប់ការសម្អាត។
- ❑ ប្រសិនបើប្រព័ន្ធប្រភេទនៃការណាត់ជួប មិនអាចធ្វើទៅបានទេនោះ, រក្សាការឃ្លាតឆ្ងាយរាងកាយពីគ្នា ដោយបិទរាល់ម៉ាស៊ីននៅចន្លោះគ្នា ដើម្បីរក្សាអោយចម្ងាយរាងកាយ រវាងភ្ញៀវម្នាក់ទៅម្នាក់ទៀត នៅឃ្លាតគ្នាចម្ងាយប្រហែល ៦ ហ្វីត។
- ❑ លើកទឹកចិត្តអោយភ្ញៀវរង់ចាំនៅខាងក្រៅ ខណៈពេលបោកគក់កំពុងបោកគក់/ហាល។ ដោយជំនួស, ប្រើសញ្ញាមើលឃើញ ដើម្បីណែនាំភ្ញៀវ ត្រង់កន្លែងដែលត្រូវឈរ, ហើយកំរឹតការចូល ដើម្បីអោយភ្ញៀវម្នាក់ៗ អាចប្រើម៉ាស៊ីនច្រើន ដែលនៅជុំគ្នា។
- ❑ កំណត់ថា តើសមត្ថភាពអតិបរិមាចំនួនមនុស្សប៉ុន្មាននាក់ គួរមានសម្រាប់ទំហំបន្ទប់ ហើយដាក់ផ្លាកសញ្ញាសំគាល់នៅលើទ្វារ

ដែលបញ្ជាក់ថា តើមានមនុស្សប៉ុន្មាននាក់អាចនៅក្នុងបន្ទប់បាន ក្នុងពេលតែមួយ, រួមជាមួយនឹងកាលវិភាគ ធ្វើការសំអាត និង សំទ្បាប់មេរោគ ។

## C. វិធានការណ៍នានា សំរាប់ការគ្រប់គ្រងការឆ្លង

- ❑ ទាក់ទងអ្នកភ្ញៀវដែលបានធ្វើការកក់នៅឯជំរុំបោះតង់ និងសួនឧទ្យាន RV មុនពេលថ្ងៃដែលបានគ្រោងទុករបស់ពួកគេ មកដល់ ដើម្បីបញ្ជាក់អំពីការកក់ ហើយសួរថា តើពួកគេ ឬនរណាម្នាក់ នៅក្នុងគ្រួសាររបស់ពួកគេ កំពុងបង្ហាញរោគសញ្ញានានា នៃជំងឺ COVID-19។ ប្រសិនបើភ្ញៀវ ឆ្លើយបញ្ជាក់រៀបចំពេលវេលាឡើងវិញ ឬលុបចោលការកក់។
- ❑ អនុវត្តន៍ការសម្អាតអោយបានហ្មត់ចត់ នៅគ្រប់តំបន់ដែលមានចរាចរណ៍ខ្ពស់ ដូចជា កន្លែងឆែកឆេរភ្ញៀវចូល និងកន្លែងរងចាំ, មជ្ឈមណ្ឌលភ្ញៀវ, បន្ទប់សម្រាកបុគ្គលិក, បន្ទប់ទឹក, និងតំបន់ដែលមានសិទ្ធចូលនិងចេញ, រួមទាំងជណ្តើរ និងរនាំងដៃ, អោយបានពេញមួយថ្ងៃ។
- ❑ សំទ្បាប់មេរោគអោយបានញឹកញាប់ លើផ្ទៃ និងរបស់របរទាំងឡាយ ដែលត្រូវបានប្រើជាទូទៅ រួមមានទាំង ដៃចង្កូតយានយន្ត, និងហ្គាប្តូរលេខ, កូនសោរ, ឧបករណ៍ប្រដាប់ប្រដារ, ក្បាលរូប៊ីណេ, កន្លែងចាក់សំរាម, កន្លែងកៅអីអង្គុយ, ឧបករណ៍ចែករំលែក, ដៃទ្វារ, ផ្ទៃខាងលើតុ, បង្គន់, និងកន្លែងលាងដៃ។

- ❑ ប្រតិបត្តិករកំសាន្តក្រៅផ្ទះ គួរពិគ្រោះជាមួយអ្នកផលិតគ្រឿងបរិក្ខារ ដើម្បីកំណត់ជំហ៊ាននានា នៃការសំទ្បាប់មេរោគ ដែលសមស្រប ជាពិសេសសម្រាប់ផ្ទៃទន់ៗ, ដែលមានប្រហោង។ លើកទឹកចិត្តភ្ញៀវអោយយក និងប្រើឧបករណ៍ផ្ទាល់ខ្លួនរបស់ពួកគេ នៅកន្លែងណាដែលអាចធ្វើទៅបាន។
- ❑ បំពាក់កន្លែងទទួលភ្ញៀវ និងកន្លែងឆែកឆេរ ឬពិនិត្យចេញចូល និងស្ថានីយ៍ធ្វើការរបស់បុគ្គលិក ជាមួយនិងផលិតផលអនាម័យនានា អោយបានត្រឹមត្រូវ, រួមទាំងប្រដាប់ធ្វើអនាម័យដៃ និងក្រណាត់ជូតសំទ្បាប់មេរោគ។
- ❑ សំភារៈប្រើប្រាស់សំរួល រួមមានផែនទីផ្លូវលំ, សៀវភៅ, ទស្សនាវដ្តី, កាហ្វេ, ទឹក, ស្ថានីយ៍បំរើសេវាកម្មខ្លួនឯង (លើកលែងតែមិនមានការប៉ះពាល់), និងរបស់របរផ្សេងទៀតសម្រាប់ភ្ញៀវ ត្រូវតែដកចេញពីកន្លែងទទួលភ្ញៀវដើម្បីជួយកាត់បន្ថយចំណុចប៉ះពាល់ និងអន្តរកម្មរបស់ភ្ញៀវ។ ផែនទីផ្លូវលំ, និងសម្ភារៈព័ត៌មានបោះពុម្ពផ្សេង ទៀតអាចត្រូវបានចែកចាយ ដល់ភ្ញៀវទេសចរណ៍នៅពេលមកដល់ សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់ពួកគេនិមួយៗ។
- ❑ លំបាកក្នុងការសំអាត និងរបស់របរដែលមានការប៉ះពាល់ជាទូទៅ, រួមមានទាំងល្បែងក្តារ ឬសៀវភៅដែលបានចែករំលែក, មិនគួរត្រូវអោយភ្ញៀវទេសចរណ៍ខ្ចីឡើយ ប្រសិនបើអាច។ ប្រសិនបើអោយខ្ចីរបស់របរដូចនោះ សូមពិចារណាដាក់របស់របរដែលបានប្រគល់ត្រឡប់មកវិញ នៅក្នុងប្រដាប់ទុកដាក់ ឬកុងតឺន័រ យ៉ាងហោចណាស់បីថ្ងៃ មុនពេលប្រគល់ទៅអោយភ្ញៀវផ្សេងទៀតខ្ចី។

- ❑ អនុវត្តតាមគោលការណ៍ណែនាំរបស់ CDC ស៊ីដើម្បីធានាថា ប្រព័ន្ធទឹកទាំងអស់ មានសុវត្ថិភាពក្នុងការប្រើប្រាស់ បន្ទាប់ពីការបិទទឹកន្លែងយ៉ាងយូរមកហើយនោះ ដើម្បីកាត់បន្ថយហានិភ័យនៃជំងឺលាកសួត (Legionnaires) និង ជំងឺដ៏ទៃៗទៀត ដែលទាក់ទងនឹងទឹក។
- ❑ ជាញឹកញាប់ កន្លែងបន្ទប់ទឹក ដែលមិនមានទឹកប្រើប្រាស់ ដូចជា, បង្គន់ចល័ត និងបង្គន់តុដេក, មិនត្រូវបានស្តុកទុក នូវផលិតផលធ្វើអនាម័យដៃទេ។ លើកទឹកចិត្តភ្ញៀវទេសចរណ៍អោយត្រៀមលក្ខណៈដើម្បីនាំយកមកជាមួយនូវប្រដាប់ ធ្វើអនាម័យដៃផ្ទាល់ខ្លួនរបស់ពួកគេ ដែលមានជាតិអាល់កុល យ៉ាងហោចណាស់ ៦០% សម្រាប់ប្រើប្រាស់នៅក្នុង កន្លែងទាំងអស់នោះ។ ប្រសិនបើបានផ្តល់អោយ, ត្រូវប្រាកដថាស្ថានីយ៍លាងដៃចល័ត ត្រូវបានថែទាំ ហើយសាប៊ូ, កន្សែង, និងការផ្គត់ផ្គង់ទឹក ត្រូវបានរក្សាទុកអោយបានពេញ។
- ❑ សំអាតកន្លែងបន្ទប់ទឹក នៅតាមពេលវេលាកំណត់ អោយបានច្រើនបំផុត ដើម្បីរក្សាពួកគេអោយបានស្អាត និងលើក ទឹកចិត្តអ្នកបោះជំរុំ និងភ្ញៀវទេសចរណ៍ប្រើវា, ដោយហេតុថា ដើម្បីបញ្ចៀសអោយអ្នកបោះជំរុំបដិសេធ មិនប្រើបន្ទប់ទឹក ដែលកខ្វក់ និងគ្មានអនាម័យ ហើយប្រើទីធ្លាខាងក្រៅជំនួសវិញ។ នៅកន្លែងដែលអាចធ្វើបាន, ចូរដាក់គំរបកន្លែង អង្គុយ ដែលអាចបោះចោលបាន នៅក្នុងបន្ទប់ទឹក។
- ❑ លើកលើកទឹកចិត្តភ្ញៀវទេសចរណ៍ អោយខ្ចប់យកចេញ នូវអ្វីដែលពួកគេខ្ចប់យកចូលមក, នៅពេល អាចធ្វើទៅបាន, ដើម្បីកាត់ បន្ថយ នូវចំនួនសំរាមត្រូវបោះចោលនៅកន្លែងជំរុំ, សួនឧទ្យាន, ដើមផ្លូវលំ, ឬកន្លែងផ្សេងៗទៀត។

- ❑ ស្ថានីយ៍ចាក់ទឹក, ស្ថានីយ៍ចាក់សំរាម RV, និងស្ថានីយ៍ចាក់បំពេញប្រូភេន ត្រូវតែសំអាត និងសំឡាប់មេរោគ ជារៀង រាល់ថ្ងៃ ហើយបុគ្គលិកគួរជូតសំអាតសំភារៈ បន្ទាប់ពីការប្រើប្រាស់រួចម្តងៗ។ ប្រសិនបើអាចធ្វើបាន, សូមដាក់ប្រដាប់ ធ្វើអនាម័យដៃ នៅជិតកន្លែងទាំងនេះ សម្រាប់ភ្ញៀវ និងបុគ្គលិកប្រើប្រាស់។
- ❑ បុគ្គលិកគួរចៀសវាងការចែករំលែកឧបករណ៍, ទូរស័ព្ទ, គ្រឿងអេឡិចត្រូនិច, និងសម្ភារៈការិយាល័យតាមដែលអាច ធ្វើទៅបាន, ហើយបើអាចធ្វើទៅបាន, ធានាថាកម្មករ មានស្ថានីយ៍ធ្វើការសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់ពួកគេ។ កុំ ចែករំលែក PPE។
- ❑ នៅពេលជ្រើសរើសសារធាតុគីមីលាងសម្អាត, និយោជិកគួរតែប្រើផលិតផលទាំងឡាយ ដែលត្រូវបានអនុម័តអោយ ប្រើប្រាស់ប្រឆាំងនឹងជំងឺ COVID-19 នៅក្នុងបញ្ជីស្ថាប័នការពាររបស់ទីភ្នាក់ងារការពារបរិស្ថាន (EPA) - បញ្ជី N និង ធ្វើតាមការណែនាំផលិតផល។ ប្រើថ្នាំសំឡាប់មេរោគ ដែលមានស្លាកសញ្ញា ថាមានប្រសិទ្ធភាពប្រឆាំងនឹងភ្នាក់ងារ បង្ករោគតាមមាត់, ដំណោះស្រាយរំលាយថ្នាំសំឡាប់មេរោគ ក្នុងផ្ទះដែលរលាយ (៥ ស្លាបព្រាបាយ ក្នុងមួយហ្គាឡុង ទឹក), ឬដំណោះស្រាយអាល់កុល ដែលមានជាតិអាល់កុលយ៉ាងតិច ៧០% ដែលសមស្របសម្រាប់ផ្ទៃ។ ផ្តល់ការ ប ណ្តុះបណ្តាលដល់បុគ្គលិក អំពីការណែនាំរបស់អ្នកផលិត និងតម្រូវការ Cal/OSHA សម្រាប់ការប្រើប្រាស់ប្រកប ដោយសុវត្ថិភាព។ កម្មករដែលប្រើប្រដាប់សំអាត ឬប្រដាប់សំឡាប់មេរោគ គួរតែពាក់ស្រោមដៃ និងឧបករណ៍ការពារ ផ្សេងៗទៀត តាមតម្រូវការ ដោយផលិតផល។

- ❑ បន្ទាប់ពីការស្នាក់នៅរបស់ភ្ញៀវទេសចរណ៍ម្នាក់ៗ, គ្រឿងបរិក្ខារសំរួលនៅតាមកន្លែងនីមួយៗ គួរតែត្រូវបានជូតចោល, សំអាត, និងសំឡាប់មេរោគ អោយបានត្រឹមត្រូវ។ នេះរួមបញ្ចូលទាំង ប្រដាប់អាំងសាច់ BBQ, កៅអី, និងកន្លែង អង្គុយ បន្ទាប់បន្សំទាំងអស់ (ឧទាហរណ៍ ទោង ឬកៅអីអង្គុយ), កន្លែងវិលទឹក, និងឧបករណ៍ភ្ជាប់អគ្គិសនី RV និង កន្លែងភ្ជាប់ទឹក។
- ❑ ត្រូវប្រាកដថា កម្មករទាំងអស់ ត្រូវបានបណ្តុះបណ្តាលអោយប្រើ និងមានគ្រឿង ផ្គត់ផ្គង់សំរាប់រាល់គោលបំណង ទាំងអស់អោយបានគ្រប់គ្រាន់ នូវគ្រឿងសំអាត និងគ្រឿងសំឡាប់មេរោគ, នៅពេលចាំបាច់។
- ❑ ត្រូវប្រាប់កម្មករយាម និងថែរក្សា ប្រសិនបើពួកគេ នឹងទៅធ្វើការនៅកន្លែងដែលមានអ្នកឆ្លងមេរោគបានទៅ។ សេវាកម្មសំអាតដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ របស់ភាគីទីបី ត្រូវបានណែនាំអោយធ្វើការសំអាតចោល ឬធ្វើកុំអោយមានការឆ្លងមេរោគ នៅតំបន់ទាំងឡាយ ដែលបានទទួលរងផលប៉ះពាល់។
- ❑ ប្រសិនបើកម្មករយាម ឬអ្នកថែរក្សា ត្រូវបានគេស្នើសុំអោយសំឡាប់មេរោគតំបន់មួយដែលមានករណីដែលគេស្គាល់ថា COVID-19, ពួកគេមិនត្រូវចាប់ផ្តើមប្រតិបត្តិការឡើយ រហូតដល់កន្លែងបោះជំរុំ ឬប្រតិបត្តិករ RV បានផ្តល់ឧបករណ៍ការពារ និងការបណ្តុះបណ្តាលត្រឹមត្រូវ។ កម្មករយាម ឬអ្នកថែរក្សា ត្រូវពាក់ស្រោមដៃដែលអាចចោលបានសម្រាប់គ្រប់ភារៈកិច្ច ក្នុងគ្រប់ដំណើរការនៃការសម្អាតទាំងអស់, រួមទាំងការធ្វើការជាមួយនឹងសំរាម។ កម្មករគួរត្រូវបានរំលឹកអោយលាងដៃជាមួយសាប៊ូ និងទឹកភ្លាមៗ បន្ទាប់ពីដោះស្រោមដៃចេញរួច ឬប្រើប្រាស់ទឹកធ្វើអនាម័យដៃ។ PPE បន្ថែមអាចនឹងមានតំរូវការ រួមទាំង វ៉ែនតាភ្នែក, ដោយផ្អែកលើផលិតផលលាងសម្អាត/ថ្នាំសំឡាប់មេរោគ ដែលកំពុងត្រូវបានប្រើ និងថាតើ មានហានិភ័យនៃការខ្ទាតបែកខ្ចាយដែរឬទេ។
- ❑ កម្មករយាម ត្រូវតែទទួលបាននូវការបណ្តុះបណ្តាល និងព័ត៌មានស្តីពីគ្រោះថ្នាក់ របស់អ្នកសំអាត និងថ្នាំសំឡាប់ មេរោគដែលត្រូវបានប្រើប្រាស់, លទ្ធភាពទទួលបាននូវសន្លឹកទិន្នន័យសុវត្ថិភាព, PPE ដែលមានតំរូវការ និងខ្យល់ ចេញចូលដែលមានតំរូវការ។
- ❑ កម្មករគួរតែមានខ្យល់ចេញចូលគ្រប់គ្រាន់ (លំហូរខ្យល់) នៅក្នុងតំបន់ទាំងឡាយ ដែលពួកគេកំពុងសម្អាត។ ប្រសិនបើការសំអាត នៅក្នុងបន្ទប់ទឹក ឬកន្លែងតូចផ្សេងទៀត, ត្រូវប្រាកដថាទ្វារ និងបង្អួច ត្រូវបានបើកចំហរ។
- ❑ ដើម្បីកាត់បន្ថយហានិភ័យនៃជំងឺហឺត ទាក់ទងនឹងការសំឡាប់មេរោគ, កម្មវិធី គួរមានគោលបំណងជ្រើសរើសផលិតផលសំឡាប់មេរោគ ក្នុងបញ្ជី N ជាមួយនឹងគ្រឿងផ្សំដែលមានសុវត្ថិភាពជាងសំរាប់ជំងឺហឺត (អ៊ីដ្រូសែនផេរុកស៊ែយ, ស៊ីទ្រីចអាស៊ីត ឬឡាក់ទិកអាស៊ីត)។ ជៀសវាងផលិតផលដែលលាយគ្រឿងផ្សំទាំងនេះ ជាមួយអាស៊ីតផេរ៉ូស៊ីយ៉ាសេទិច, សូដ្យូមហ៊ីប៉ូក្លរីត (ប្លីច) ឬសមាសធាតុអាម៉ូញ៉ូមខ្វរធើណារី, ដែលអាចបង្ករអោយមានជំងឺហឺត។
- ❑ អ្នកទេសចរណ៍ទីធ្លាបោះជំរុំ និងសួនឧទ្យាន RV ត្រូវបានរំលឹកអោយរក្សាចម្ងាយ ៦ ហ្វីត ពីការថែទាំ, អ្នកយាម, ឬបុគ្គលិកថែរក្សា នៅក្រុមថែទាំ។ អនុវត្តដំណើរការត្រួតពិនិត្យ ឬផែកឆេរបុគ្គលិកពេលចូលធ្វើការ ជាមួយកម្មករអោយបានទៀងទាត់ ដើម្បីធានាថាភ្ញៀវទេសចរណ៍ទាំងឡាយ កំពុងអនុវត្តតាមពិធីការនេះ។ ធានាថាកម្មករទាំងឡាយ អាច

ចែករំលែកព័ត៌មានបែបនេះដោយគ្មានការភ័យខ្លាចនៃការគុំគួន ឬការសងសឹក។

- ❑ ប្រតិបត្តិការកន្លែងបោះជំរុំ និងសួនឧទ្យាន RV គួរតែវាយតម្លៃ ថាតើសួនឧទ្យានផ្ទៃនៅមានទំហំទីធ្លាធំល្មម អាចផ្ទុកភ្ញៀវទេសចរណ៍ និងសត្វរបស់ពួកគេបានដែរឬទេ ខណៈពេលដែលរក្សានូវការឃ្លាតឆ្ងាយរាងកាយពីគ្នា។ ប្រសិនបើទីធ្លាទំនេរមិនគ្រប់គ្រាន់ទេនោះ, សួនឧទ្យានផ្ទៃត្រូវតែត្រូវបានពង្រីក, កំរិតនូវការកាន់កាប់, ឬបិទ។

## D. វិធានការណ៍នានា ដែលទំនាក់ទំនងទៅកាន់សាធារណៈជន

- ❑ ប្រតិបត្តិករកន្លែងបោះជំរុំ និងសួនឧទ្យាន RV គួរតែចាត់វិធានការណ៍ដើម្បីធានាថា អ្នកទេសចរណ៍បានដឹងច្បាស់ អំពីគោលនយោបាយ និងនីតិវិធីថ្មីរបស់សួនឧទ្យាន មុនពេលពួកគេមកដល់។ គោលនយោបាយបែបនេះ គួរតែរាប់បញ្ចូលនូវសិទ្ធិនៃប្រតិបត្តិករ កន្លែងបោះជំរុំ និងសួនឧទ្យាន RV ក្នុងការលុបចោលនូវការកក់ សម្រាប់ភាគីទាំងឡាយដែលមានភ្ញៀវទេសចរណ៍មានរោគសញ្ញា; នីតិវិធីពិនិត្យ ឬផែកឆេចូលថ្មី; តម្រូវការឃ្លាតឆ្ងាយរាងកាយពីគ្នា; និងការសំអាត និងរំងាប់មេរោគ, កាលវិភាគសម្រាប់ការសំអាត និងរំងាប់មេរោគនៅកន្លែងស្នាក់នៅ, របស់របរប្រើប្រាស់. និងតំបន់រួមនានា ដូចជាតំបន់ឆែកឆេរចូល/ចុះឈ្មោះ និងហាងលក់ទំនិញឧទ្យានទូទៅ ឬមជ្ឈមណ្ឌលភ្ញៀវទេសចរណ៍។
- ❑ ផ្តល់ព័ត៌មានដល់ភ្ញៀវទេសចរណ៍លើប្រធានបទ ដូចខាងក្រោម៖
    - o រៀបចំផែនការទុកជាមុន, ធ្វើការកក់ទុក និងទិញនូវការអនុញ្ញាត, អុស, ទឹកកក និងរបស់របរផ្សេងទៀត តាមអនឡាញ ឬតាមទូរស័ព្ទ មុនពេលទៅដល់កន្លែង។
    - o ត្រូវចេះទប់ចិត្ត និងមានការគ្រប់គ្រាន់ចំពោះខ្លួនឯង តាមដែលអាចធ្វើទៅបាន។ ឧទាហរណ៍, មកដល់កន្លែងដែលបានរៀបចំជាស្រេច នូវសាប៊ូផ្ទាល់ខ្លួន, គ្រឿងផ្គត់ផ្គង់ សំលាប់មេរោគលើផ្ទៃ, ទឹកធ្វើអនាម័យដៃ, កន្សែងក្រដាស/កន្សែងដៃ, និងក្រដាសបង្គន់។ វាក៏ត្រូវបានគេណែនាំអោយមកនូវ ប្រដាប់ជូតរំងាប់មេរោគ ដើម្បីធ្វើការសម្អាត មុននិងក្រោយពេលប្រើប្រាស់កន្លែងរួមរួច។ សូមយកមកនូវសម្ភារៈកីឡានានា, កន្សែង, ឧបករណ៍ជំនួយដំបូងនានា, និងរបស់របរផ្សេងទៀត ដែលត្រូវការសម្រាប់ការកំសាន្ត នៅក្រៅផ្ទះ នៅពេលណាដែលអាចធ្វើទៅបាន។ ទេសចរណ៍គួរយកគំរបតុប្លាស្ទិចសម្រាប់តុពិចនិច ដែលអាចយកទៅបោះចោលបាន ឬយកទៅផ្ទះវិញដើម្បីបោក។
    - o ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា, ភ្ញៀវទេសចរណ៍ គួរតែរៀបចំកន្លែងបោះជំរុំ ឬតំបន់ពិចនិចរបស់ពួកគេ ដើម្បីបង្កើនចម្ងាយពីកន្លែងបោះជំរុំ និងកន្លែងពិចនិចជិតៗ ដែលអាចផ្ទុកមនុស្សមកពីគ្រួសារ ផ្សេងៗគ្នា។
    - o កម្មវិធី និងកន្លែងជាច្រើន អាចត្រូវបានលុបចោល ឬបិទ, ដូច្នេះភ្ញៀវទេសចរណ៍ គួរតែពិនិត្យមើលធនធានតាមអនឡាញសម្រាប់ព័ត៌មានថ្មីៗអំពីការផ្លាស់ប្តូរច្បាប់ និងការបិទដើម្បី ដឹងពីអ្វីដែលត្រូវរំពឹង នៅពេលមក

ដល់។

- o សង្កេតមើលរាល់ពិធីការសម្អាត សម្រាប់គ្រឿងបរិក្ខារសេវាកម្ម និងរបស់របរដែលបំរើដោយខ្លួនឯង មុនពេលប្រើវា។
- o ទុកគ្រឿងសង្ហារិម, ដូចជា តុ និងកៅអីពិចនិច, ព្រោះពួកគេត្រូវបានគេរកឃើញថា បុគ្គលិកសួនឧទ្យាន អាចទុកដាក់អោយមានចន្លោះរបស់របរទាំងអស់នោះ ដើម្បីលើកទឹកចិត្តដល់ការឃ្លាតឆ្ងាយរាងកាយពីគ្នា។
- o អនុវត្តតាមផ្លាកសញ្ញាទិសដៅ - ឧទាហរណ៍, រង់ចាំវេនរបស់អ្នក ហើយគោរពទៅតាមការកំរឹតសមត្ថភាព - ដែលនឹងជំរុញអោយមានការឃ្លាតឆ្ងាយរាងកាយពីគ្នានៅក្នុងអាគារ, ការមើលរំលង និងនៅជុំវិញកន្លែងទំនេរផ្សេងទៀត។
- o រៀបចំផែនការធ្វើដំណើររបស់អ្នកតាមរបៀបប្រកបដោយសុវត្ថិភាព និងការទទួលខុសត្រូវ។ សូមចងចាំថាប្រតិបត្តិការតាមជនបទ និងជំនួយតាមជនបទ តម្រូវអោយមានអ្នកឆ្លើយតបគ្រាអាសន្នជាច្រើន និងមានមានការស្នើសុំបន្ថែម លើធនធានថែទាំសុខភាពទាំងនោះ ដែលធ្វើអោយមនុស្សគ្រប់គ្នាមានគ្រោះថ្នាក់។

- ❑ រក្សាប្រព័ន្ធទំនាក់ទំនង ដែលអនុញ្ញាតិអោយ បុគ្គលិកនិងភ្ញៀវទេសចរណ៍ រាយការណ៍រោគសញ្ញាដោយខ្លួនឯង និងទទួលបានការជូនដំណឹងភ្លាមៗនៃការប្រឈម និងការទៅជិត, ខណៈពេលដែលរក្សាបាននូវការសម្ងាត់។
- ❑ ច្បាប់ចតចំលងពិធីការនេះ ត្រូវបានបិទផ្សាយនៅតាមច្រកចូលសាធារណៈ នៅតាមទីធ្លាជុំវិញនានា។
- ❑ ផ្លាកសញ្ញានានា ត្រូវបានបិទផ្សាយដែលណែនាំដល់ភ្ញៀវទេសចរណ៍ ថាពួកគេគួរតែស្នាក់នៅផ្ទះ ប្រសិនបើឈឺ ដោយមានរោគសញ្ញានានា ដែលអាចជាជំងឺ COVID-19។
- ❑ អនឡាញអៅឡែតនៃទីកន្លែង (គេហទំព័រ, ប្រព័ន្ធផ្សព្វផ្សាយសង្គម ។ល។) ផ្តល់នូវព័ត៌មានច្បាស់លាស់អំពី, ពិធីការបច្ចុប្បន្ននានា, តំរូវការប្រើប្រាស់គម្របមុខ, ការអនុវត្តការត្រួតពិនិត្យការឆ្លង និងតម្រូវការឃ្លាតឆ្ងាយ រាងកាយពីគ្នា។

## E. វិធានការណ៍នានា ដែលធានានូវការទទួលបានសេវាកម្មចាំបាច់ ប្រកបដោយសមធម៌

- ❑ សេវាកម្មនានាដែលមានសារៈសំខាន់សម្រាប់ភ្ញៀវទេសចរណ៍ ត្រូវបានផ្តល់អាទិភាព។
- ❑ វិធានការណ៍នានា ត្រូវបានបង្កើតឡើង ដើម្បីធានានូវសេវាកម្មសម្រាប់ភ្ញៀវទេសចរណ៍ ដែលមានកម្រិតនៃការចល័ត និង/ឬ មានហានិភ័យខ្ពស់នៅក្នុងទីធ្លាសាធារណៈ។

វិធានការណ៍បន្ថែមណាមួយ ដែលមិនបានដាក់បញ្ចូលខាងលើ គួរតែត្រូវបានដាក់វាយនៅលើទំព័រដាច់ដោយឡែក, ដែលអាជីវកម្ម គួរតែភ្ជាប់ជាមួយនឹងឯកសារនេះ។

អ្នកអាចទាក់ទងមនុស្សខាងក្រោមនេះ បើសិនជាអ្នកមានសំណួរ ឬយោបល់នានា អំពីពិធីការនេះ:

ឈ្មោះទំនាក់ទំនងអាជីវកម្ម: ________________________________________

លេខទូរស័ព្ទ: ________________________________________

កាលបរិច្ឆេទកែប្រែចុងក្រោយ: ________________________________________

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**